# មិត្តភាព
# ដ៏ពិត

## នាំមកជូនដោយនំម៉ាណាប្រចាំថ្ងៃ


និពន្ធដោយ

H. Dennis Fisher ◆ Julie Ackerman Link ◆ Dave Branon

David C. Egner ◆ Joseph M. Stowell

កែសម្រួលអត្ថបទជាភាសាអង់គ្លេសដោយ

Anne Cetas, Managing Editor ◆ Becky Knapp, Associate Editor

Tim Gustafson, J.R. Hudberg, Judith Markham, Editors

រចនារូបភាពដោយ

Heri Kurniawan

ក្រាហ្វិកដោយ

Vania Tan/Mary Tham

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក លី ប៊ុនថា

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា



បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និង

រក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2018 ODB Ministries (website: www.odb.org)



ចេញផ្សាយដោយ : ODB Cambodia (email: cambodia@odb.org, Tell: 087 233 907,

website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb)

# សួស្ដី មិត្តភក្ដិទាំងឡាយ!

តើជីវិតរបស់យើងនឹងកាន់តែមានភាពស្រស់បំព្រងយ៉ាងណា នៅពេលដែលយើងបានឆ្លងកាត់បទពិសោធន៍នៃជីវិត ជាមួយមិត្តសំឡាញ់របស់យើងនោះ?

ក្នុងនាមយើងជាជីវិតដែលមានការទំនាក់ទំនងគ្នា យើងត្រូវការមិត្តភាព ដែលមិត្តសំឡាញ់នាំចូលក្នុងជីវិតយើង និងត្រូវការទំនាក់ទំនងដែលយើងកសាងជាមួយពួកគេ។ មិត្តសំឡាញ់អាចជួយកម្សាន្តចិត្តយើង នៅពេលដែលយើងបាក់ទឹកចិត្ត ព្រមទាំងចូលរួមអរសប្បាយជាមួយយើង នៅពេលដែលយើងមានចិត្តសប្បាយរីករាយ ហើយក៏ជួយយើង នៅពេលដែលយើងស្ថិតក្នុងភាពខ្វះខាត។ ពួកគេយំសោកជាមួយយើង ព្រមទាំងសើចជាមួយផង ហើយរួមសុខរួមសុខទុក្ខជាមួយយើង ក្នុងគ្រប់កាលៈទេសៈទាំងអស់។

ខណៈពេលដែលយើងស្វែងរក ហើយចាត់ទុកមិត្តសំឡាញ់ ជាកំណប់ទ្រព្យដ៏មានតម្លៃ នោះ យើងក៏ត្រូវមានចិត្តចង់ធ្វើជាមិត្តល្អ សម្រាប់ពួកគេផងដែរ។ ប៉ុន្តែតើធ្វើដូចម្ដេច ទើបយើងអាចក្លាយជាមិត្តសំឡាញ់ដ៏ពិតបាន? តើធ្វើដូចម្ដេច ឲ្យយើងអាចពង្រឹងមិត្តភាព ឲ្យកាន់តែរឹងមាំឡើង? តើនរណា អាចធ្វើជាមួយមិត្តសំឡាញ់ "ដ៏ល្អឥតខ្ចោះ" របស់យើង? យើងខ្ញុំសង្ឃឹមថា អ្នកនឹងទទួលបានការលើកទឹកចិត្ត តាមរយៈសៀវភៅសម្រាប់ប្រកបជាមួយព្រះប្រចាំថ្ងៃ រយៈពេលប្រាំពីរថ្ងៃនេះ ខណៈពេលដែលអ្នកស្វែងយល់ អំពីអត្ថន័យ នៃមិត្តភាពដ៏ពិត។

អត្ថបទនីមួយៗ សម្រាប់អានប្រចាំថ្ងៃនេះ មានបញ្ចូលខគម្ពីរ និងអត្ថបទ ព្រមទាំងមានសំណួរមួយ ឬពីរភ្ជាប់មកជាមួយផងដែរ។ យើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យចំណាយពេលអាន និងសិក្សាខគម្ពីរទាំងនោះ រួចពិចារណា អំពីព្រះបន្ទូលដែលអ្នកនិពន្ធបានឆ្លុះបញ្ចាំង ហើយឆ្លើយសំណួរទាំងប៉ុន្មាន ដែលយើងខ្ញុំបានផ្ដល់ឲ្យ។

សូមយើងឲ្យតម្លៃ ចំពោះមិត្តភាពរបស់យើង ដ្បិតពួកគេមានតម្លៃដ៏វិសេស។

# មិត្តភាព

ក្នុងនាមជាជីវិតដែលមាន
ការប្រាស្រ័យទាក់ទងគ្នា
យើងត្រូវការមិត្តភក្តិ សម្រាប់
រួមដំណើរ ក្នុងជីវិតយើង។

តើមិនអស្ចារ្យទេឬ ដែលយើង
មានមិត្តសំឡាញ់ ដែលអាចរួមដំណើរ
ជាមួយយើង ឆ្លងកាត់ភាពទ្បើងចុះ
នៃជីវិត?

សូមយើងឲ្យតម្លៃ ចំពោះមិត្តភាព
របស់យើង ដ្បិតមិត្តភាពមានតម្លៃ
ណាស់។

ថ្ងៃទី ១

# អត្ថប្រយោជន៍ នៃមិត្តភាព

**សូមអាន:** សាស្តា ៤:៩-១២

លោកស៊ីសេរ៉ូ (Cicero) ស្ថិតក្នុងចំណោមអ្នកប្រាជ្ញ ដ៏ល្បីល្បាញម្នាក់ នៅចក្រភពរ៉ូម៉ាំង។ គាត់ជា វាគ្មិនប្រកបដោយវោហារសាស្ត្រ មេធាវី អ្នកនយោបាយ ភាសាវិទូ និងជាអ្នកនិពន្ធ ដ៏ស្ទាត់ជំនាញ។ សព្វថ្ងៃនេះ គេនៅតែដកស្រង់ពាក្យសម្តីរបស់គាត់មកប្រើ ព្រោះសំណេររបស់គាត់មានភាពសាមញ្ញ និងច្បាស់លាស់ ហើយទស្សនវិជ្ជារបស់គាត់ទៀតសោត ក៏សមស្រប សម្រាប់ការរស់នៅជាក់ស្តែង។

ឧទាហរណ៍ គាត់បានមានប្រសាសន៍ អំពីការរាប់អានមិត្តភក្តិថា "មិត្តភាពបង្កើនសុភមង្គល និងកាត់បន្ថយទុក្ខព្រួយ តាមរយៈការបន្ថែមអំណរទ្វេរដង ហើយចែករំលែកទុក្ខព្រួយ"។ គាត់យល់ថា មិត្តភាពមានអត្ថប្រយោជន៍ទ្វេរដង នៅលើវិថីជីវិត។ នៅមុខសម័យរបស់លោកស៊ីសេរ៉ូ ប្រហែលជិត១ ពាន់ឆ្នាំ ស្តេចសាឡូម៉ូនក៏បានសរសេរ អំពីតម្លៃរបស់មិត្តសំឡាញ់ផងដែរ។ គឺដូចដែលទ្រង់បានថែងក្នុងកណ្ឌគម្ពីរសាស្តាថា "មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង ពីព្រោះគេមានរង្វាន់យ៉ាងល្អកើតពីការនឿយហត់របស់ខ្លួន ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ តែវរហើយអ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ" (៤:៩-១០)។ ជាការពិតណាស់ ជីវិតដែលគ្មានមិត្តសំឡាញ់ ធ្វើឲ្យការធ្វើដំណើរមានភាពឯកោ និងពិបាកទ្រាំទ្រ។

ទាំងអ្នកប្រាជ្ញជនជាតិរ៉ូម៉ាំង និងស្តេចដែលជាអ្នកប្រាជ្ញជនជាតិយូដានោះ សុទ្ធតែនិយាយត្រូវណាស់។ មិត្តសំឡាញ់ គឺសំខាន់។ មិត្តសំឡាញ់អាចធ្វើជាអ្នក ដែលយើងអាចទុកចិត្ត និងជាអ្នកប្រឹក្សាយោបល ហើយថែមទាំងជួយរំលែកទុក្ខព្រួយផង។ សូមគិតអំពីមិត្តសំឡាញ់របស់អ្នកចុះ។ តើអ្នកធ្លាប់បានព្រងើយកន្តើយ នឹងមនុស្សដែលព្រះទ្រង់បានប្រទានមក ដើម្បីជួយរំលែកក្តីអំណរ និងទុក្ខព្រួយរបស់អ្នកឬទេ? បើសិនជាដូច្នោះមែន សូមស្វែងរកមិត្តភក្តិណាម្នាក់ ដើម្បីធ្វើការប្រកបគ្នា នៅសប្តាហ៍នេះចុះ។ សូមចាំថា "មានគ្នាពីរនាក់ នោះវិសេសជាង នៅតែម្នាក់ឯង" ព្រោះមិត្តសំឡាញ់នឹងបង្កើនអំណរទ្វេដង និងជួយរំលែកទុក្ខព្រួយផងដែរ។ - HDF

តើអ្នកចង់អរព្រះគុណដល់ព្រះជាម្ចាស់ សម្រាប់នរណាខ្លះ ដែលទ្រង់បានប្រទានមក ឲ្យរួមដំណើរ និងរួមសុខទុក្ខជាមួយអ្នក នៅក្នុងជីវិតនេះ? សូមធ្វើអ្វីមួយ ដើម្បីបង្ហាញការសរសើរ និងឲ្យតម្លៃចំពោះពួកគេ នៅថ្ងៃនេះ។

____________________

____________________

____________________



មិត្តសំឡាញ់ ប្រៀបដូចជាផ្កា
ដែលដុះ នៅក្នុងសួនច្បារនៃជីវិត។

ថ្ងៃទី ២



# មនុស្សសុចរិត ជាអ្នកចាំផ្លូវដល់ អ្នកជិតខាង។

សុភាសិត ១២:២៦



# មិត្តល្អ

**សូមអាន :** ១សាំយ៉ូអែល ១៨:១-៤

មានពេលមួយខ្ញុំបានបង្កើតគណនេយ្យថ្មីមួយ ក្នុងហ្វេសប៊ុក ដែលជាបណ្តាញសង្គមដ៏ពេញនិយម លើប្រព័ន្ធអ៊ីនធើណិត។ ពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើល ពេលដែលបានទទួលការស្វាគមន៍ថា "អ្នកគ្មានមិត្តភក្តិទេ"។ ទោះបីជាខ្ញុំដឹងថា វាមិនពិតក៏ដោយ ខ្ញុំនៅតែមានអារម្មណ៍មិនសប្បាយចិត្ត ក្នុងពេលនោះ។ កាលណាគេថា ខ្ញុំគ្មានមិត្តភក្តិ នោះខ្ញុំមិនសប្បាយចិត្ត ទោះអ្នកថានោះជាវែបសាយ នៅតាមបណ្តាញអ៊ីនធើណិតក៏ដោយ។ មិត្តសំឡាញ់សំខាន់ចំពោះសុខុមាលភាព ទាំងផ្លូវអារម្មណ៍ និងផ្លូវកាយ ព្រមទាំងខាងវិញ្ញាណ។

មិត្តសំឡាញ់ចំណាយពេលស្តាប់រឿងឈឺចាប់របស់យើង ដោយមិនស្តីបន្ទោសយើង ដោយសារតែបញ្ហាដែលយើងមាននោះឡើយ។ ពួកគេការពារយើង នៅពេលដែលយើងរងការវាយប្រហារ។ ពួកគេនឹងអរសប្បាយ នៅពេលដែលយើងជោគជ័យ ហើយមិនសប្បាយចិត្ត នៅពេលដែលយើងបរាជ័យ។ ពួកគេជួយគំនិតយ៉ាងឈ្លាសវៃ ដើម្បីកុំឲ្យយើងធ្វើការសម្រេចចិត្តដ៏ល្ងីល្ងើ។ ពួកគេថែមទាំងហ៊ានប្រថុយ នឹងការកែតម្រង់យើង ដោយមិនខ្លាចយើងខឹង ដើម្បីឲ្យយើងមានភាពត្រឹមត្រូវ។ មិត្តភក្តិរបស់ខ្ញុំបានធ្វើការទាំងអស់នេះដល់ខ្ញុំ ហើយច្រើនជាងនេះផង។

មិត្តភាពរវាងយ៉ូណាថាន និងដាវីឌ ប្រហែលជាមិត្តភាពដែលគេបានចាប់អារម្មណ៍ច្រើនជាងគេ ក្នុងព្រះគម្ពីរ(១សាំយូអែល ១៨:១-៤)។ យ៉ូណាថាន ជាអ្នកដែលត្រូវស្នងរាជបល្ល័ង្ក បន្តពីស្តេចសូល ដែលជាបិតា។ ប៉ុន្តែ គាត់ដឹងថា ព្រះអម្ចាស់បានជ្រើសរើសដាវីឌ ឲ្យទទួលតួនាទីនេះ បានជាគាត់ហ៊ានប្រថុយជីវិត ដើម្បីជួយសង្គ្រោះដាវីឌ ដែលជាសំឡាញ់របស់ខ្លួន។

ព្រះគម្ពីរបានប្រាប់យើង ឲ្យជ្រើសរើសមិត្តសំឡាញ់ ដោយប្រុងប្រយ័ត្ន(សុភាសិត ១២:២៦)។ មិត្តល្អ គឺជាអ្នកដែលបានធ្វើជាមិត្តសំឡាញ់របស់ព្រះជាម្ចាស់ និងជាអ្នកដែលជួយពង្រឹងទំនាក់ទំនងដែលយើងមានជាមួយទ្រង់(១សាំយូអែល ២៣:១៦)។ - JAL

តើអ្នកចង់អរព្រះគុណដល់ព្រះជាម្ចាស់ សម្រាប់នរណាខ្លះ ដែលទ្រង់បានប្រទានមក ឲ្យរួមដំណើរ និងរួមសុខទុក្ខជាមួយអ្នក នៅក្នុងជីវិតនេះ? សូមធ្វើអ្វីមួយ ដើម្បីបង្ហាញការសរសើរ និងឲ្យតម្លៃចំពោះពួកគេ នៅថ្ងៃនេះ។

____________________

____________________

____________________

____________________

____________________

____________________

ថ្ងៃទី ៣



## មិត្តសំឡាញ់ កម្ររកបានណាស់ ដូច្នេះ យើងត្រូវ បង្កើតមិត្តភាព។

- WENTWORTH

# ធ្វើដូចម្តេច ឱ្យយើងអាចក្លាយជាមិត្តល្អ

**សូមអាន** សុភាសិត ២៧:៦-១៧

មែលីស្សា(Melissa)កូនស្រីរបស់ខ្ញុំ មានមិត្តភក្តិច្រើន ក្នុងអំឡុងពេលរៀននៅវិទ្យាល័យ។ ក្នុងចំណោមមិត្តល្អ ទាំងនោះ នាងមានមិត្តល្អម្នាក់ឈ្មោះ ខេធី(Katie)។ ក្រោយពេលដែលម៉េលីស្សាបានបាត់បង់ជីវិត ក្នុងគ្រោះថ្នាក់ចរាចរ ខេធីបានប្រាប់ខ្ញុំ អំពីរបៀបដែលពួកគេបាន ក្លាយជាមិត្តភក្តិ។

កាលនោះ ខេធីគឺជាសិស្សថ្មី នៅថ្នាក់ទី៥ ដោយនាងទើបតែផ្ទេរមកពីរដ្ឋកាលីហ្វូញ៉ា។ នាងមាន អារម្មណ៍ឯកោ ហើយមិនទាន់ស៊ាំនឹងកន្លែងថ្មី រហូត ដល់ថ្ងៃមួយ ដែលត្រូវជាដើមឆ្នាំដំបូងរបស់នាង នៅទី នោះ។ គឺពេលនោះហើយ ដែលមែលីស្សាបានកត់ សម្គាល់ឃើញនាង កំពុងអង្គុយម្នាក់ឯងក្នុងឡានក្រុង។

មែលីស្សាក៏បានក្រោកចេញ ពីកៅអីរបស់នាង ទៅអង្គុយក្បែរខេធីវិញ ហើយក៏បានចាប់ផ្តើមសាកសួរ ពីនេះពីនោះ។ ចាប់តាំងពីពេលនោះមក ពួកគេក៏បាន អង្គុយនៅក្បែរគ្នា ជារៀងរាល់ថ្ងៃ ហើយបានក្លាយជាមិត្ត សំឡាញ់ ដែលមិនអាចបំបែកបាន អស់រយៈពេលប្រាំ ពីរឆ្នាំ រហូតដល់ពេលដែលមែលីស្សាទៅនៅជាមួយព្រះ អម្ចាស់ នៅនគរស្ថានសួគ៌។

ក្នុងពិភពលោកយើងនេះ មានមនុស្សច្រើន ណាស់ អាចមានការផ្លាស់ប្រែក្នុងជីវិត ដោយសារទង្វើរ នៃសេចក្តីស្រឡាញ់ ដែលអ្នកដទៃបានធ្វើសម្រាប់ពួក គេ តែមួយលើកប៉ុណ្ណោះ។ មនុស្សទាំង នោះប្រហែល ធ្លាប់គិតថា ពួកគេមិនអាចចូលក្នុងចំណោមគេចុះ ឬ ពួកគេប្រហែលជាកំពុងប្រឈមមុខនឹងបញ្ហាលំបាក ដែលធ្វើឲ្យពួកគេមានអារម្មណ៍ឯកោ។ ពេលខ្លះ អ្វីដែល យើងត្រូវធ្វើនោះ គឺគ្រាន់តែឈោងទៅរកពួកគេ ឬ បង្ហាញទឹកមុខញញឹម ឬក៏និយាយពាក្យលើកទឹកចិត្ត ប៉ុណ្ណោះ។ យើងរាល់គ្នា ដែលជាអ្នកជឿព្រះ សុទ្ធតែ បានស្គាល់ ហើយបានពិសោធនឹងសេចក្តីស្រឡាញ់ របស់ព្រះអង្គ(១យ៉ូហាន ៣:១៦) ដូចនេះ យើងអាច ឈោងទៅរកមនុស្សជាច្រើន ហើយចែករំលែកសេចក្តី ស្រឡាញ់ នោះ។

ក្នុងសង្គមដែលយើងរស់នៅសព្វថ្ងៃ មាន មនុស្សច្រើនល្មម នឹងឲ្យមនុស្សម្នាក់អាចរាប់អានគ្នាជា មិត្តភក្តិបាន។ សូមធ្វើជាអ្នកចាប់ផ្តើមរាប់អានគេមុន ដើម្បីកុំឲ្យមាននរណាម្នាក់ នៅម្នាក់ឯង ដោយគ្មានគេ រាប់រកនោះឡើយ។ - JDB

តើមានអ្នកណាខ្លះ ដែលអ្នកអាចប្រព្រឹត្តល្អប្រកប ដោយសេចក្តីស្រឡាញ់ដល់ពួកគេ នៅថ្ងៃនេះ?

ថ្ងៃទី ៤

# តើអ្នកយកចិត្តទុកដាក់ ចំពោះមិត្តភក្តិរបស់អ្នកដែរឬទេ?

**សូមអាន** ១សាំយូអែល ២០:១-២៣

ការដែលអ្នកប្រាប់មិត្តភក្តិរបស់អ្នកថា អ្នកយកចិត្តទុកដាក់ ចំពោះពួកគេ គឺជារឿងល្អហើយ។ ប៉ុន្តែ តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីបង្ហាញឲ្យពួកគេដឹងថា អ្នកពិតជាយកចិត្តទុកដាក់មែន? នៅពេលដែលដាវីឌ និងយ៉ូណាថានបានចងសម្ព័ន្ធមិត្តភាព(១សាំយូអែល ១៨:១-៤) អ្នកទាំងពីរសុទ្ធតែមិនបានដឹងថា យ៉ូណាថាននឹងហ៊ានលះបង់ដល់កម្រិតណា ដើម្បីបង្ហាញការយកចិត្តទុកដាក់ ចំពោះដាវីឌឡើយ។ ប៉ុន្តែ ដែលដឹងឬអត់ គឺមិនសំខាន់ទេ។ យ៉ូណាថានមិនបានរួញរានឹងគ្រោះថ្នាក់ទេ ដោយគាត់បានប្រព្រឹត្តដោយចិត្តក្លាហាន ដើម្បីជួយសង្គ្រោះជីវិតដាវីឌ(២០:១-២៣)។

នៅពេលដែលយើងកសាងមិត្តភាព កាន់តែជិតស្និទ្ធ យើងក៏ត្រូវបង្ហាញឲ្យគេដឹងថា យើងពិតជាខ្វល់អំពីពួកគេមែន តាមរយៈសកម្មភាពរបស់យើង។ ពាក្យថា "យកចិត្តទុកដាក់" ក្នុងភាសាអង់គ្លេស គេប្រើពាក្យ C-A-R-E ដែលមានអក្សរបួនតួ។ ពាក្យនេះអាចជួយឲ្យយើងចងចាំ អំពីធាតុផ្សំសំខាន់ៗ នៃមិត្តភាព។

CHALLENGE: អ្នកត្រូវជំរុញចិត្តមិត្តភក្តិរបស់អ្នក ឲ្យលូតលាស់ឡើងខាងវិញ្ញាណ។ មិត្តភក្តិល្អយល់ច្បាស់ អំពីសារៈសំខាន់នៃការបង្វែរការសន្ទនា ឲ្យងាកទៅរកការជជែកអំពីសេចក្តីជំនឿ។

AFFIRM: អ្នកត្រូវបញ្ជាក់ អំពីតម្លៃរបស់មិត្តភក្តិអ្នក។ ការទូរស័ព្ទទៅកាន់មិត្តភក្តិ ឬការសរសេរសំបុត្រដ៏ខ្លី ផ្ញើទៅពួកគេ អាចធ្វើឲ្យពួកគេដឹងថា ពួកគេមានតម្លៃចំពោះអ្នក ហើយក៏អាចរក្សាមិត្តភាពកាន់តែរឹងមាំ។





**RESPECT:** អ្នកត្រូវមានការគោរពចំពោះអារម្មណ៍ និងបំណងប្រាថ្នានៃមិត្តភក្តិរបស់អ្នក។ គ្មានអ្នកណាចង់មានមិត្តភក្តិ ដែលមិនចេះស្តាប់គំនិត ក្តីស្រមៃ និងក្តីបារម្ភរបស់ខ្លួននោះទេ។ មិត្តល្អគឺជាឧបករណ៍ថតសម្លេងដ៏អស្ចារ្យ។

**ENCOURAGE:** អ្នកត្រូវលើកទឹកចិត្តមិត្តភក្តិរបស់អ្នក តាមរយៈការសរសើរ និងការធ្វើអំពើល្អដល់គាត់។ មិត្តភក្តិរបស់អ្នកនឹងមានអារម្មណ៍ធូរស្បើយ បន្ទាប់ពីបាននៅក្បែរអ្នក។

តើអ្នកមានមិត្តភក្តិ ដែលអ្នកគួរតែយកចិត្តទុកដាក់ នៅថ្ងៃនេះឬទេ ? – JDB

*តើធ្វើដូចម្តេច ឲ្យអ្នកអាចបង្ហាញមិត្តភក្តិរបស់អ្នកថា អ្នកយកចិត្តទុកដាក់ចំពោះពួកគេ ?*

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

## មិត្តសំឡាញ់ដ៏ពិត គឺជាអំណោយមកពីព្រះជាម្ចាស់ ហើយជាមនុស្សម្នាក់ ដែលជួយបង្ហាញផ្លូវយើងឲ្យវិលទៅរកព្រះអង្គ។

ថ្ងៃទី ៥

# ការរាប់អាន ដែលរាក់កំផែល

**សូមអាន** យ៉ូហាន ១៥:៩-១៧

ថ្មីៗនេះ មានមនុស្សម្នាក់បានទូរស័ព្ទមកខ្ញុំ។ ការនិយាយស្តីរបស់គាត់ហាក់ដូចជារួសរាយណាស់។ នាងប្រាប់ខ្ញុំថា នាងចង់ធ្វើឲ្យការរស់នៅរបស់ខ្ញុំ មានភាពងាយស្រួលជាងមុន។ នាងបានហៅឈ្មោះរបស់ខ្ញុំ ហើយក៏បានសួរអំពីសុខទុក្ខរបស់ខ្ញុំ តាមរបៀបដ៏កក់ក្តៅ។ បន្ទាប់មក នាងបានណែនាំខ្ញុំថា នាងអាចជួយខ្ញុំឲ្យអាចសន្សំប្រាក់រាប់ពាន់ដុល្លា ក្នុងមួយឆ្នាំ ដោយគ្រាន់តែទៅទទួលប្រាក់កម្ចីសម្រាប់ចំណាយក្នុងផ្ទះ ពីក្រុមហ៊ុនបញ្ចាំទ្រព្យ។ ប៉ុន្តែ ក្រោយពេលដែលនាងដឹងថា ខ្ញុំមិនមានចំណាប់អារម្មណ៍ ការរាក់ទាក់របស់នាងក៏បានរលាយបាត់មួយរំពេច។

ការរាក់ទាក់ដែលមិនស្មោះត្រង់បែបនោះ គឺគ្រាន់តែជាអាកប្បកិរិយាគួរសមក្នុងសង្គម ដែលមនុស្សខ្លះប្រើ ដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីអ្នកដទៃ ឬដើម្បីទាញយកផលប្រយោជន៍ ពីពួកគេប៉ុណ្ណោះ។

យើងមិនត្រូវមានអាកប្បកិរិយាអាត្មានិយមដូចនេះទេ តែត្រូវជំនួសមកវិញ ដោយមិត្តភាពដ៏ពិត ដូចដែលព្រះយេស៊ូវបានបង្ហាញដល់យើង។ ទ្រង់មានបន្ទូលថា "គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ" (យ៉ូហាន ១៥:១៣)។ បន្ទាប់មក ទ្រង់បានបង្ហាញសេចក្តីស្រឡាញ់ដែលលះបង់ ដល់យើងរាល់គ្នា តាមរយៈការសុគតនៅលើឈើឆ្កាង ដើម្បីលើកលែងទោសបាបឲ្យយើងរាល់គ្នា។

នៅពេលដែលយើងទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះ ហើយរៀនស្តាប់បង្គាប់ទ្រង់ យើងនឹងបានពិសោធន៍នឹងមិត្តភាពដ៏ជ្រាលជ្រៅ ដែលបង្ហាញចេញនូវភាពរួសរាយ ដ៏ពិតប្រាកដ និងស្មោះត្រង់ ចំពោះអ្នកដទៃ។

ឱ ព្រះ អម្ចាស់ សូមជួយយើងខ្ញុំ ឲ្យចៀសវាងការរាប់អានគ្នា ដែលរាក់កំផែល ដែលគ្រាន់ តែដើម្បីទទួលប្រយោជន៍នោះឡើយ។ តែសូមទ្រង់បង្រៀនយើងខ្ញុំ ឲ្យបង្ហាញចេញនូវការរាប់អានដ៏ពិត និងកក់ក្តៅដូចព្រះគ្រីស្ទ ទៅកាន់មនុស្សគ្រប់គ្នា ដែលយើងខ្ញុំជួប។

- DCE

តើការរាប់អានគ្នាដ៏ពិត ដូចព្រះគ្រីស្ទ មានលក្ខណៈដូចម្តេច? តើយើងអាចចៀសវាងការរាប់អានដែលរាក់កំផែល ដោយរបៀបណា?

______________________________



ការរាប់អាន ពិតប្រាកដ
អាចជាមេដែក ដែលទាក់ទាញ
មនុស្សឲ្យចូលទៅ
រកព្រះគ្រីស្ទ។

ថ្ងៃទី ៦

# ពាក្យសម្ដីដែល មុតស្រួចដូចដាវ

**សូមអាន** យ៉ូហាន ១៥:៩-១៧

ព្រះគម្ពីរសុភាសិតបានពណ៌នាថា មនុស្សឥតប្រាជ្ញា ជាមនុស្សដែលពោលពាក្យឥតបើគិត "ដូចជាចាក់ដោយដាវ" (សុភាសិត ១២:១៨)។ អណ្ដាតរបស់មនុស្សអាចធ្វើជាកាំបិត ដែលមានមុខច្រើន ដូចកាំបិតរបស់កងទ័ពស្វីស ពីព្រោះមនុស្សយើងអាចប្រើប្រាស់អណ្ដាត កាប់ ចាក់ ឬកាត់ ដើម្បីបំផ្លាញគ្នាទៅវិញទៅមកតាមរបៀបជាច្រើន។

ពាក្យសម្ដីដែលធ្វើឲ្យខូចខាត អាចបណ្ដាលឲ្យកើតមានកំហឹង អារម្មណ៍រំខាន ភាពនឿយណាយ ភាពឆេវឆាវ និងថែមទាំងការខកចិត្ត ភាពតានតឹង ការប្រកាន់ទោស និងការភ័យខ្លាច។ ហើយកាលណាមនុស្សយើងកាប់ចាក់គ្នា ដោយពាក្យសម្ដី នោះមានន័យថា យើងកំពុងតែធ្វើឲ្យមិត្តភាព និងទំនាក់ទំនងរងរបួស ហើយបែកបាក់គ្នា។ ហេតុដូច្នេះហើយ ទើបព្រះគម្ពីរប្រាប់យើងថា "ការសាបព្រោះសេចក្ដីទាស់ទែងគ្នាក្នុងពួកបងប្អូន" ស្ថិតក្នុងចំណោមការប្រាំពីរយ៉ាងដែលជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់(សុភាសិត ៦:១៦-១៩)។

តើធ្វើដូចម្ដេច ទើបយើងអាចចៀសផុត ពីការទាំងនោះបាន? ជាដំបូង យើងត្រូវតែប្រុងប្រយ័ត្នចំពោះអ្វីដែលយើងត្រូវនិយាយ។ យើងមិនត្រូវឲ្យមានការនិយាយដើមគ្នា និងការមួលបង្កាច់គ្នា ហើយមិនត្រូវប្រើពាក្យសម្ដីណា ដែលបង្កឲ្យមានការឈឺចាប់ ប៉ុន្តែ ត្រូវនិយាយតែពាក្យសម្ដីទាំងឡាយណា ដែលនាំមកនូវការប្រោសឲ្យជាវិញ។ យើងត្រូវជម្រុះចោល ការអួតបំប៉ោង និងការកុហក និងអស់ទាំងពាក្យសម្ដី ដែលបង្កការឈឺចាប់ និងការទាស់ទែងគ្នា។ ផ្ទុយទៅវិញ យើងត្រូវនិយាយតែពាក្យសម្ដីដែលនាំឲ្យមានសេចក្ដីស្រឡាញ់ ការប្រោសឲ្យជា និងការអត់ទោស ការសណ្ដោសប្រណី



# ពាក្យសម្ដីរបស់យើង
# មានអំណាចស្ថាងឡើង
# ក៏ដូចជាបំផ្លាញផងដែរ។

និងនិយាយតែការពិត ដោយឲ្យសេចក្ដីល្អទាំងនេះ គ្រប់គ្រងទំនាក់ទំនង និងពាក្យសម្ដីរបស់យើង។ សរុបមក តើយើងរាល់គ្នានឹងទៅជាយ៉ាងណា បើសិនជាព្រះយេស៊ូវមិនបានមានបន្ទូល ប្រកបដោយសេចក្ដីស្រឡាញ់ ព្រមទាំងព្រះគុណ និងការអត់ទោស ដល់យើងរាល់គ្នាទេនោះ?

ដូច្នេះ សូមទម្លាក់ពាក្យសម្ដីដែលមុតដូច "ដាវ" ចុះ ហើយសូមប្រើពាក្យសម្ដី ដើម្បីជួយ និង ប្រោសឲ្យជាវិញ។ - JMS

តើមានពាក្យសម្ដីអ្វីខ្លះ ដែលអ្នកគួរតែចៀសវាង ហើយអ្នកត្រូវនិយាយពាក្យសម្ដីអ្វីខ្លះ ដើម្បីជួយ និងប្រោសឲ្យជា ដល់មិត្តភាពរបស់អ្នក?

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________

______________________________



ថ្ងៃទី ៧



# មិត្តភាពជាមួយព្រះ ជាមិត្តភាពដ៏ពិត មិនមែនជាការស្រមើស្រមៃ

**សូមអាន** រ៉ូម ១:១៨-២៥

កាលពីពេលកន្លងទៅ ខ្ញុំបានឮគេនិយាយអំពីផ្ទាំងផ្សព្វផ្សាយនៅតាមដងផ្លូវ ដែលមានសរសេរអក្សរពីលើថា "ព្រះជាម្ចាស់គ្រាន់តែជាមិត្តភក្តិ មានតែក្នុងការស្រមើស្រមៃប៉ុណ្ណោះ សូមជ្រើសរើសអ្វីដែលពិតជាមានមែន។ ធ្វើយ៉ាងនេះ ទើបមានប្រយោជន៍ជាង សម្រាប់យើងរាល់គ្នា"។

ជាក់ស្តែង ពាក្យនេះប្រៀបធៀបគ្រីស្ទបរិស័ទ ទៅនឹងកូនក្មេង ដែលមានក្តីស្រមៃដ៏រស់រវើក ដល់ថ្នាក់ធ្វើឲ្យពួកគេអាចប្រឌិតឡើង នូវមិត្តភក្តិ ដែលអាចលេងជាមួយពួកគេបាន។ ប៉ុន្តែ តើព្រះទ្រង់គ្រាន់តែជាមិត្តភក្តិ ក្នុងក្តីស្រមៃប៉ុណ្ណោះឬ?

ជាការពិតណាស់ មានភស្តុតាងបញ្ជាក់ច្បាស់ថា ព្រះពិតជាមានមែន។ សូមពិចារណា អំពីការបកស្រាយដូចតទៅ : តាមការសិក្សា អំពីកំណើតរបស់ផែនដី បានបង្ហាញឲ្យយើងដឹងថា ចក្រវាលទាំងមូលបានកើតឡើងពីការរចនារបស់ព្រះ គឺមិនមែនកើតឡើងដោយឯកឯងឡើយ(រ៉ូម ១:១៨-២០)។ មនុស្សម្នាក់ៗសុទ្ធតែមានសតិសម្បជញ្ញៈ ដែលដឹងខុសត្រូវ ជាភស្តុតាងបញ្ជាក់ថា មានព្រះមួយអង្គ ដែលបានប្រទានច្បាប់ នៅក្នុងគំនិតយើងដែលឲ្យអាចយើងដឹងខុសត្រូវ(រ៉ូម ២:១៤-១៥)។ ភាពប៉ិនប្រសប់ដែលមនុស្សយើងបានបង្ហាញចេញ នៅក្នុងជួរ

**មិត្តជិតស្និទ្ធបំផុត នៅលើផែនដីនេះ គឺគ្រាន់តែជាស្រមោល បើយើងប្រៀបធៀប នឹងព្រះយេស៊ូវ។ — Chambers**





តន្ត្រី និងសិល្បៈ គឺបានឆ្លុះបញ្ចាំង អំពីភាពប៉ិនប្រសប់ ដែលព្រះអាទិករមាន (និក្ខមនំ ៣៥:៣១-៣២)។ ព្រះគ្រីស្ទបានបង្ហាញឲ្យមនុស្សដឹងថា ព្រះជាម្ចាស់មានលក្ខណៈសម្បត្តិយ៉ាងណា ពេលដែលទ្រង់យកកំណើតជាមនុស្ស(ហេព្រើរ ១:១-៤)។ ហើយសេចក្តីរួបរួមគ្នា និងការប្រកបស្និតស្នាលនៃព្រះវិញ្ញាណបរិសុទ្ធ ដែលមានក្នុងចិត្តរបស់គ្រីស្ទបរិស័ទ គឺបានបង្ហាញថា ព្រះជាម្ចាស់ពិតជាមានមែន(កាឡាទី ៥:២២-២៣)។

ព្រះគម្ពីរបានប្រាប់យើងថា មនុស្សនឹងបដិសេធមិនព្រមជឿថា ព្រះជាម្ចាស់ពិតជាមានមែន (២ពេត្រុស ៣:៤-៦)។ ប៉ុន្តែ លោកយ៉ាកុបបានរំឭកយើងថា ព្រះជាម្ចាស់ពិតជាមានមែន ហើយក៏បាននិយាយអំពី មនុស្សម្នាក់ដែលបានធ្វើជាមិត្តសំឡាញ់ជាមួយទ្រង់ នៅគ្រាសញ្ញាចាស់។ គឺដូចដែលគាត់បានមានប្រសាសន៍ថា “អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក។ ព្រះក៏ហៅលោកជាសំឡាញ់របស់ទ្រង់ដែរ”(យ៉ាកុប ២:២៣)។ តើអ្នកបានជួបព្រះដ៏ប្រោសលោះហើយឬនៅ? ព្រះអង្គបានប្រទានព្រះរាជបុត្រាទ្រង់តែ១ ឲ្យយាងមកធ្វើជាមិត្តសំឡាញ់ដ៏ពិត ហើយអស់កល្បជានិច្ចរបស់អ្នក (យ៉ូហាន ១៥:១៥)។ - HDF

ព្រះយេស៊ូវសព្វព្រះទ័យនឹងធ្វើជាមិត្តសំឡាញ់របស់អ្នក ដែលនេះជាឯកសិទ្ធិដ៏វិសេស។ តើអ្នកបានធ្វើជាមិត្តសំឡាញ់របស់ទ្រង់ហើយឬនៅ?

________________________________________

________________________________________

________________________________________



## ODB MINISTRIES ASIA-PACIFIC OFFICES

Please direct all correspondence to the office nearest you.

**ODB Ministries Australia Limited**

PO Box 15, Kilsyth, VIC 3137, Australia

Tel: (+61-3) 9761 7086, Fax: (+61-3) 8080 3235, Email: australia@Odb.org

**ODB Ministries Ltd (Hong Kong)**

KCL Box 74025, Kowloon Central Post Office, Kowloon, Hong Kong

Tel: (+852) 2626 1102, Fax: (+852) 2626 0216, Email: hongkong@odb.org

**ODB Indonesia**

PO Box 2500, Jakarta 11025, Indonesia

Tel: (+62-21) 2902 8950, Fax: (+62-21) 5435 1975, Email: indonesia@odb.org

**ODB Ministries Japan**

PO Box 46, Ikoma Nara 630-0291, Japan

Tel: (+81-743) 75 8230, Fax: (+81-743) 75 8299, Email: japan@odb.org

**ODB Resource Centre Berhad**

PO Box 86, Taman Sri Tebrau, 80057 Johor Bahru, Malaysia

Tel: (+60-7) 353 1718, Fax: (+60-7) 353 4439, Email: malaysia@odb.org

**ODB Ministries New Zealand**

PO Box 303095, North Harbour, Auckland 0751, New Zealand

Tel: (+64-9) 444 4146, Fax: (+64-9) 444 4156, Email: newzealand@odb.org

**ODB Ministries Foundation**

PO Box 47-260, Taipei 103, Taiwan R.O.C.

Tel: (+886-2) 2585 5340, Fax: (+886-2) 2585 5349, Email: taiwan@odb.org

**ODB Ministries Thailand**

PO Box 35, Huamark, Bangkok 10243, Thailand

Tel: (+66-2) 718 5166, Fax: (+66-2) 718 6016, Email: thailand@odb.org

**ODB Ministries Asia Limited**

MacPherson Road Post Office, PO Box 146, Singapore 913405

Tel: (+65) 6858 0900, Fax: (+65) 6858 0400, Email: singapore@odb.org

**ODB Ministries USA**

PO Box 2222, Grand Rapids, MI 49501-2222, USA

Tel: (+1-616) 974 2210, Fax: (+1-616) **957** 5741, Email: usa@odb.org

For a detailed listing of our offices, go to **ourdailybread.org/locations**.